ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:..៤៤៧....ប្រ.ក....ប.ស្ក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងសំណល់អាគុយ និងសំណល់ថ្មពិល

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង



អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងសំណល់បរិក្ខាអគ្គិសនី និងអេឡិចត្រូនិក
- បានឃើញប្រកាសលេខ ៣៨៧ ប្រក.បស្ថ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យបោះបង់ចោល
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងសំណល់អាគុយ និងសំណល់ថ្មពិលប្រកបដោយសុវត្ថិភាពបរិស្ថាន។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- គ្រប់គ្រងសំណល់អាគុយ និងសំណល់ថ្មពិល ចាប់ពីចំណុចបង្កើតរហូតដល់បោះចោលចុងក្រោយ
- ទប់ស្កាត់រាល់ការសាយភាយសារធាតុគ្រោះថ្នាក់ ពីសំណល់អាគុយនិងសំណល់ថ្មពិលចូលក្នុងបរិស្ថាន
- ទប់ស្កាត់ការនាំចូលសំណល់អាគុយ និងសំណល់ថ្មពិលក្នុងគោលបំណងស្តុក ធ្វើប្រព្រឹត្តិកម្ម និងបោះបង់ចោល
- លើកកម្ពស់ការអនុវត្តអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងសំណល់អាគុយ និងសំណល់ថ្មពិល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចខាងក្រោម៖

- **សំណល់អាគុយ** សំដៅដល់ប្រភេទអាគុយ(អាគុយស្ងួត ឬអាគុយសើម) ឬថ្មសាក(ឧបករណ៍ស្តុកថាមពល"Powerbank") ទាំងឡាយណា ដែលខូចមិនអាចប្រើប្រាស់ឡើងវិញបាន និងត្រូវបានបោះបង់ចោល។

- **សំណល់ថ្មពិល** សំដៅដល់ប្រភេទថ្មពិលគ្រប់ប្រភេទដែលខូច មិនអាចប្រើប្រាស់ឡើងវិញបាន និងត្រូវបោះបង់ចោល ។

## ជំពូកទី ២
## ការគ្រប់គ្រង និងនីតិវិធីសុំលិខិតអនុញ្ញាត

**ប្រការ៥..**

លំនៅដ្ឋានទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម និងសិប្បកម្ម មានកាតព្វកិច្ចទុកដាក់ និងរៀបចំបែងចែកសំណល់អាគុយនិងសំណល់ថ្មពិលដាច់ដោយឡែកពីសំណល់ផ្សេងទៀត ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត។

**ប្រការ៦..**

ការប្រមូល ការស្តុក ការដឹកជញ្ជូន ការដោះបំបែក និងការធ្វើប្រព្រឹត្តិកម្មសំណល់អាគុយ និងសំណល់ថ្មពិល ក្នុងបំណងយកសំណ ឬសារធាតុផ្សេងៗទៀត និងការបោះបង់ចោលត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។

រាល់ការប្រមូល ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោលសំណល់អាគុយ និងសំណល់ថ្មពិលត្រូវមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ។

**ប្រការ៧..**

រាល់អាជីវកម្មសំណល់អាគុយ ដែលមានលក្ខណៈជាអាជីវកម្មគ្រួសារត្រូវសុំលិខិតអនុញ្ញាតពីមន្ទីរបរិស្ថានរាជធានី-ខេត្ត (ដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ១)។

រាល់អាជីវកម្មសំណល់អាគុយ ដែលមានលក្ខណៈជាអាជីវកម្មខ្នាតតូចនិងមធ្យម ឬអាជីវកម្មខ្នាតធំត្រូវសុំលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន (ដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ២)។

**ប្រការ៨..**

រាល់ការនាំចេញសំណល់អាគុយ និងសំណល់ថ្មពិល ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅអាចនឹងត្រូវប្រព្រឹត្តទៅបានលុះត្រាតែមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញ របស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតឱ្យនាំចូលរបស់សាមីប្រទេសជាមុនសិន (ដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ៣)។

**ប្រការ៩..**

ហាមដាច់ខាតរាល់ការដុត ឬវាយបំបែកសំណល់អាគុយ និងសំណល់ថ្មពិលដែលបង្កឱ្យប៉ះពាល់ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងបរិស្ថាន។

**ប្រការ១០..**

កម្រៃសេវានៃការស្នើសុំការប្រមូល ការស្តុក ការដឹកជញ្ជូន ការដោះបំបែកសំណល់អាគុយ និងសំណល់ថ្មពិលក្នុងបំណងយកសំណ ឬសារធាតុផ្សេងៗ ការធ្វើប្រព្រឹត្តិកម្ម ការបោះបង់ចោល និង

ការបង្កើតទីលានសុវត្ថិភាពត្រូវអនុវត្តតាមប្រកាសរួម ស្តីពីសេវាសាធារណៈចំពោះសំណល់គ្រោះថ្នាក់រវាង ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ៣
## ភារកិច្ច និងការទទួលខុសត្រូវ

**ប្រការ១១.-**

ម្ចាស់អាជីវកម្ម ត្រូវមានភារកិច្ចរាយការណ៍ជូនមន្ទីរបរិស្ថាន ឬក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង ពីការវិវឌ្ឍនូវរាល់ការប្រមូល ការស្តុក ការទុកដាក់ ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោលសំណល់អាគុយ និងសំណល់ថ្មពិល នៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន ដើម្បីធានានូវ សុវត្ថិភាពបរិស្ថាន និងសុខភាពសាធារណៈ។

**ប្រការ១២.-**

មន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវមានភារកិច្ចតាមដាន និងរាយការណ៍ជូនក្រសួងបរិស្ថាន រៀងរាល់ ៣ខែម្តង ពីការវិវឌ្ឍនូវរាល់ការប្រមូល ការស្តុក ការទុកដាក់ ការដឹកជញ្ជូន ការដោះបំបែក ការធ្វើ ប្រព្រឹត្តិកម្ម និងការបោះបង់ចោល សំណល់អាគុយ និងសំណល់ថ្មពិលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យ បានត្រឹមត្រូវដើម្បីធានានូវសុវត្ថិភាពបរិស្ថាន និងសុខភាពសាធារណៈ។

**ប្រការ១៣.-**

នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន មានភារកិច្ចចុះត្រួតពិនិត្យតាមដាន ការបំពុលដោយអាជីវកម្ម សំណល់អាគុយ និងសំណល់ថ្មពិល និងធ្វើ ការណែនាំទៅដល់ម្ចាស់អាជីវកម្ម លើវិធានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។

## ជំពូកទី ៤
## ទណ្ឌកម្ម

**ប្រការ១៤.-**

ការមិនអនុវត្តតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅ តាមមាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ ជំពូកទី៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**ប្រការ១៥.-**

បន្ទាប់ពីប្រកាសនេះចូលជាធរមានចំពោះអាជីវកម្មដែលបាននិងកំពុងប្រកបអាជីវកម្មប្រមូល ស្តុក ទុកដាក់ ដឹកជញ្ជូន ដោះបំបែក ធ្វើប្រព្រឹត្តិកម្ម និងបោះបង់ចោលសំណល់អាគុយ និងសំណល់ថ្មពិល ក្នុងបំណងយកសំណ ឬសារធាតុផ្សេងៗទៀត ត្រូវមកបំពេញទម្រង់បែបបទស្នើសុំលិខិតអនុញ្ញាតប្រកប

អាជីវកម្មស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះក្នុងអំឡុងពេល ១២(ដប់ពីរ)ខែ គិតចាប់ពីថ្ងៃចេញប្រកាសនេះតទៅ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋាន រដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ នាយកខុទ្ទកាល័យ និងគ្រប់អង្គភាពចំណុះក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត
- មន្ទីរបរិស្ថានរាជធានី-ខេត្ត
- ដូចប្រការ ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ១

## សាលាកប័ត្រព័ត៌មាននៃការគ្រប់គ្រងសំណល់អាគុយ

១. ឈ្មោះសិប្បកម្ម៖.......................................................................................................
អាសយដ្ឋាន៖.......................................................................................................
ផ្ទៃក្រឡា.........................................ជាកម្មសិទ្ធផ្ទាល់ខ្លួន☐ ជួលពីឯកជន☐ ឬជួលពីរដ្ឋ☐
រយៈពេលវិនិយោគ/អាជីវកម្ម៖.........................បានចាប់ផ្តើមដំណើរការនៅឆ្នាំ៖...................។

២.ឯកសារភ្ជាប់៖

- លិខិតអនុញ្ញាតពីមន្ទីរពាណិជ្ជកម្ម ☐
- លិខិតអនុញ្ញាតពីមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ☐
- លិខិតអនុញ្ញាតពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ☐
- លិខិតអនុញ្ញាតផ្សេងៗ.................................

៣. ប្រភេទអាជីវកម្ម ឬសិប្បកម្ម៖

☐ ការប្រមូល ☐ ការស្តុកទុក
☐ ការដឹកជញ្ជូន ☐ ការដោះបំបែក
☐ ការធ្វើប្រព្រឹត្តិកម្ម ☐ ការបោះបង់ចោល
☐ ផ្សេងៗ...........................................................................................................

៤. ប្រភេទ និងបរិមាណសំណល់អាគុយ ដែលបានបង្កើតពីអាជីវកម្ម ឬសិប្បកម្ម៖

☐សំណល់រឹងគ្រោះថ្នាក់៖.........................................បរិមាណ.......................គ.ក្រ/ថ្ងៃ
☐សំណល់រាវគ្រោះថ្នាក់៖.........................................បរិមាណ.......................គ.ក្រ/ថ្ងៃ
☐សំណល់កកគ្រោះថ្នាក់៖.........................................បរិមាណ.......................គ.ក្រ/ថ្ងៃ
☐សំណល់ផេះគ្រោះថ្នាក់៖.........................................បរិមាណ.......................គ.ក្រ/ថ្ងៃ
☐ ផ្សេងៗ...........................................................................................................

ធ្វើនៅ...................ថ្ងៃទី............ខែ............ឆ្នាំ២០......
ហត្ថលេខា និងឈ្មោះអ្នករាយការណ៍

ឧបសម្ព័ន្ធ២

# សាលាកប័ត្រព័ត៌មាននៃការគ្រប់គ្រងសំណល់អាគុយ

១. ឈ្មោះក្រុមហ៊ុន ឬរោងចក្រ..................................................................................................
អាសយដ្ឋាន..................................................................................................................
ផ្ទៃក្រឡា...........................................ជាកម្មសិទ្ធផ្ទាល់ខ្លួន☐ ជួលពីឯកជន☐ ឬជួលពីរដ្ឋ☐
រយៈពេលវិនិយោគ/អាជីវកម្ម៖.............................បានចាប់ផ្តើមដំណើរការនៅឆ្នាំ៖....................។

២.ឯកសារភ្ជាប់៖

- លិខិតអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ☐
- លិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ☐
- លិខិតអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ☐
- លិខិតអនុញ្ញាតផ្សេងៗ..................................

៣. ប្រភេទអាជីវកម្ម ឬសិប្បកម្ម៖

☐ ការប្រមូល ☐ ការស្តុកទុក
☐ ការដឹកជញ្ជូន ☐ ការដោះបំបែក
☐ ការធ្វើប្រព្រឹត្តិកម្ម ☐ ការបោះបង់ចោល
☐ ផ្សេងៗ....................................................................................................

៤. ប្រភេទ និងបរិមាណសំណល់អាគុយ ដែលបានបង្កើតពីអាជីវកម្ម ឬសិប្បកម្ម៖

☐ សំណល់រឹងគ្រោះថ្នាក់៖.......................................បរិមាណ.......................គ.ក្រ/ថ្ងៃ
☐ សំណល់រាវគ្រោះថ្នាក់៖.......................................បរិមាណ.......................គ.ក្រ/ថ្ងៃ
☐ សំណល់កក់គ្រោះថ្នាក់៖.......................................បរិមាណ.......................គ.ក្រ/ថ្ងៃ
☐ សំណល់ផេះគ្រោះថ្នាក់៖.......................................បរិមាណ.......................គ.ក្រ/ថ្ងៃ
☐ ផ្សេងៗ....................................................................................................

ធ្វើនៅ....................ថ្ងៃទី............ខែ............ឆ្នាំ២០......
ហត្ថលេខា និងឈ្មោះអ្នករាយការណ៍

ឧបសម្ព័ន្ធ៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
**អគ្គនាយកដ្ឋានគាំពារបរិស្ថាន**

## ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញ
## សំណល់អាគុយ និងសំណល់ថ្មពិល

ឈ្មោះក្រុមហ៊ុនស្នើសុំ.................................................................................................................

ឈ្មោះអ្នកទំនាក់ទំនង......................................................ភេទ.............សញ្ជាតិ.......................

មុខងារក្នុងក្រុមហ៊ុន.................................................អត្តសញ្ញាណប័ណ្ណ.......................................

អាសយដ្ឋានក្រុមហ៊ុន៖ ផ្ទះលេខ.................ផ្លូវលេខ................ក្រុមទី..................ភូមិ.................

ឃុំ/សង្កាត់.........................................ស្រុក/ខណ្ឌ...........................ខេត្ត/រាជធានី........................

ទូរស័ព្ទ:.........................ទូរសារ:..........................សារអេឡិចត្រូនិក:.......................................

វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (អ.ត.ប) លេខ:.........................ចុះថ្ងៃទី.......ខែ.....ឆ្នាំ.......

វិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីក្នុងក្រសួងពាណិជ្ជកម្មលេខ:........................ចុះថ្ងៃទី.......ខែ.....ឆ្នាំ.......

| ល.រ | ឈ្មោះផលិតផល | គុណភាព | បរិមាណស្នើសុំ (គ្រឿង) | បន្សំសារធាតុក្នុងអាគុយ/ថ្មពិល | លេខសម្គាល់ក្នុងតារាងពន្ធគយកម្ពុជា |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |

១. ក្រុមហ៊ុនទទួលយក៖

ឈ្មោះ.................................................................................................................

អាសយដ្ឋាន...........................................................................................................

ប្រទេស..................................................................................................................

២. រោងចក្រផលិត៖

ឈ្មោះ.................................................................................................................

ប្រទេស..................................................................................................................

៣. ទីកន្លែង ឬកំពង់ផែដែលមានបំណងនាំចេញ៖

កាលបរិច្ឆេទមកដល់...........................................................................................

គោលបំណងប្រើប្រាស់.........................................................................................

ព័ត៌មានបន្ថែម:......................................................................................................

...............................................................................................................................

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ.........

ហត្ថលេខានិងត្រា ប្រធានក្រុមហ៊ុន